**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

លេខ....០៤៤.........អ.ស.ហ.ប្រ.ក

# ប្រកាស

## ស្តីពី

## វិធាន និងគោលការណ៍ណែនាំនៃការធានារ៉ាប់រងបន្ត

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធានក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៤៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨១៤/០២១ ចុះថ្ងៃទី៤ ខែសីហា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធានារ៉ាប់រង
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ
- បានឃើញអនុក្រឹត្យលេខ ២៧៥ អនក្រ.បក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការធានារ៉ាប់រង
- បានទទួលការឯកភាពពីក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ក្នុងសម័យប្រជុំនាថ្ងៃទី២ ខែកក្កដា ឆ្នាំ២០២៤

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសនេះ កំណត់អំពីវិធាន និងគោលការណ៍ណែនាំនៃការធានារ៉ាប់រងបន្ត ដើម្បីធានានូវសុវត្ថិភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រងនិងការការពារហានិភ័យរបស់ក្រុមហ៊ុនធានារ៉ាប់រង។

**ប្រការ២ .-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះក្រុមហ៊ុនធានារ៉ាប់រង ដែលកំពុងធ្វើប្រតិបត្តិការនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣ .-**

វាក្យសព្ទដែលប្រើនៅក្នុងប្រកាសនេះ មាននិយមន័យដូចខាងក្រោម៖

- **ក្រុមហ៊ុនធានារ៉ាប់រង** សំដៅដល់ក្រុមហ៊ុនធានារ៉ាប់រងអាយុជីវិត ក្រុមហ៊ុនធានារ៉ាប់រងទូទៅ ក្រុមហ៊ុនធានារ៉ាប់រងខ្នាតតូច និងក្រុមហ៊ុនធានារ៉ាប់រងបន្ត។
- **ការធានារ៉ាប់រងបន្ត** សំដៅដល់ប្រតិបត្តិការធានារ៉ាប់រងដែលក្រុមហ៊ុនធានារ៉ាប់រងដើមត្រូវបានធានារ៉ាប់រងដោយក្រុមហ៊ុនធានារ៉ាប់រងផ្សេងទៀតដែលជាក្រុមហ៊ុនធានារ៉ាប់រងបន្ត នូវហានិភ័យមួយផ្នែក ឬទាំងស្រុង ដែលខ្លួនបានចុះកិច្ចសន្យាធានារ៉ាប់រង។
- **កិច្ចព្រមព្រៀងធានារ៉ាប់រងបន្ត** សំដៅដល់កិច្ចសន្យានៃកម្មវិធីធានារ៉ាប់រងបន្តសម្រាប់គ្រប់គ្រងហានិភ័យជាក់លាក់ដែលមានចំនួនទឹកប្រាក់ដែលត្រូវបានធានារ៉ាប់រងលើសពីកម្រិតរក្សាទុកហានិភ័យ ក្រោមវិសាលភាពនៃផលិតផលធានារ៉ាប់រងនីមួយៗ។
- **កិច្ចព្រមព្រៀងធានារ៉ាប់រងបន្តបែបសមាមាត្រ** សំដៅដល់កិច្ចព្រមព្រៀងធានារ៉ាប់រងបន្តដែលក្រុមហ៊ុនធានារ៉ាប់រងដើម និងក្រុមហ៊ុនធានារ៉ាប់រងបន្ត ព្រមចែករំលែកតាមសមាមាត្រនៃបុព្វលាភធានារ៉ាប់រង និងសំណងដែលកើតឡើងដោយហានិភ័យដែលត្រូវបានធានា។
- **កិច្ចព្រមព្រៀងធានារ៉ាប់រងបន្តបែបមិនសមាមាត្រ** សំដៅដល់កិច្ចព្រមព្រៀងធានារ៉ាប់រងបន្តដែលក្រុមហ៊ុនធានារ៉ាប់រងបន្ត ធានាលើប្រាក់សំណងរបស់ក្រុមហ៊ុនធានារ៉ាប់រងដើម ដែលលើសពីចំនួនដែលបានកំណត់តាមបុព្វលាភធានារ៉ាប់រង។
- **កម្រិតរក្សាទុកហានិភ័យ** សំដៅដល់ចំនួន ឬចំណែកនៃទឹកប្រាក់ដែលត្រូវបានធានារ៉ាប់រងចំពោះហានិភ័យណាមួយដែលត្រូវបានរក្សាទុក និងត្រូវធ្វើសំណងផ្ទាល់ដោយក្រុមហ៊ុនធានារ៉ាប់រង។

- **មួយព្រឹត្តិការណ៍** សំដៅដល់ហេតុការណ៍ណាមួយដែលកើតឡើងហើយបណ្តាលឱ្យមានការខូចខាតដោយហេតុបង្កតែមួយ ក្នុងអំឡុងពេលតែមួយ និងកន្លែងតែមួយ។
- **ហានិភ័យបង្គរ** សំដៅដល់ហានិភ័យរួមដែលកើតឡើង ហើយបង្កផលប៉ះពាល់ដល់ហានិភ័យដោយឡែកជាច្រើន ក្នុងព្រឹត្តិការណ៍ណាមួយ។

## ជំពូកទី២
## ការរក្សាទុក និងការគ្រប់គ្រងហានិភ័យ

**ប្រការ៤ ._**

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវកំណត់កម្រិតរក្សាទុកហានិភ័យអតិបរមា ដោយផ្អែកលើមូលដ្ឋានមួយហានិភ័យ និងមួយព្រឹត្តិការណ៍ សម្រាប់ប្រភេទផលិតផលធានារ៉ាប់រងនីមួយៗ។

**ប្រការ៥ ._**

ក្រុមហ៊ុនធានារ៉ាប់រង មិនត្រូវចេញបណ្ណសន្យារ៉ាប់រងដែលមានចំនួនទឹកប្រាក់ដែលត្រូវបានធានារ៉ាប់រងលើសពីកម្រិតរក្សាទុកហានិភ័យ លើកលែងតែក្រុមហ៊ុនធានារ៉ាប់រងមានសមត្ថភាពទទួលយកហានិភ័យតាមរយៈការធានារ៉ាប់រងបន្តជាមុន។

## ជំពូកទី៣
## កិច្ចព្រមព្រៀងធានារ៉ាប់រងបន្ត

**ប្រការ៦ ._**

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវរៀបចំផែនការកិច្ចព្រមព្រៀងធានារ៉ាប់រងបន្តជាមួយក្រុមហ៊ុនធានារ៉ាប់រងបន្តក្នុងប្រទេស និងក្រៅប្រទេស និងត្រូវស្នើសុំការអនុញ្ញាតជាមុនពី **ន.ធ.ក.** បន្ទាប់ពីទទួលបានការសម្រេចពីក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន។

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវស្នើសុំការអនុញ្ញាតពី **ន.ធ.ក.** លើផែនការកិច្ចព្រមព្រៀងធានារ៉ាប់រងបន្តសម្រាប់ឆ្នាំបន្ទាប់ឱ្យបានមុនថ្ងៃទី១ ខែវិច្ឆិកា ជារៀងរាល់ឆ្នាំ ឬអាចស្នើសុំការអនុញ្ញាតលើផែនការកិច្ចព្រមព្រៀងធានារ៉ាប់រងបន្តសម្រាប់ផលិតផលធានារ៉ាប់រងនីមួយៗ ស្របពេលជាមួយការស្នើសុំការអនុញ្ញាតលក់ផលិតផលធានារ៉ាប់រងនោះ។

**ប្រការ៧ ._**

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវរៀបចំកិច្ចព្រមព្រៀងធានារ៉ាប់រងបន្ត ដោយផ្អែកលើមូលដ្ឋានមួយហានិភ័យ និងមួយព្រឹត្តិការណ៍។ កិច្ចព្រមព្រៀងធានារ៉ាប់រងបន្ត ត្រូវមានព័ត៌មានអប្បបរមា ដូចខាងក្រោម៖

- កម្រិតរក្សាទុកហានិភ័យ
- កម្រិតត្រូវធ្វើធានារ៉ាប់រងបន្ត
- ប្រភេទនៃកិច្ចព្រមព្រៀងធានារ៉ាប់រងបន្ត
- ក្រុមហ៊ុនធានារ៉ាប់រងបន្តគោលដៅ និងពិពិធកម្មហានិភ័យ។

**ប្រការ៨ ..**

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវស្នើសុំការអនុញ្ញាតជាមុនពី **ន.ធ.ក.** ក្នុងរយៈពេលយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ ក្នុងករណីមានការផ្លាស់ប្តូរ ឬកែប្រែកិច្ចព្រមព្រៀងធានារ៉ាប់រងបន្ត បន្ទាប់ពីទទួលបានការសម្រេចពីក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន។

**ប្រការ៩ ..**

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវប្រើប្រាស់សេណារីយ៉ូគ្រោះមហន្តរាយជាក់លាក់ ឬសេណារីយ៉ូគ្រោះមហន្តរាយ តាមរយៈការធ្វើម៉ូឌែល សម្រាប់វាយតម្លៃលើហានិភ័យបង្ករដែលអាចកើតឡើងដោយព្រឹត្តិការណ៍ណាមួយនាពេលអនាគត។

**ប្រការ១០ ..**

ក្រុមហ៊ុនធានារ៉ាប់រងបន្តក្នុងប្រទេស មានសិទ្ធិផ្តល់ការធានារ៉ាប់រងបន្តលើគ្រប់ប្រភេទហានិភ័យធានារ៉ាប់រង។

**ប្រការ១១ ..**

ក្រុមហ៊ុនធានារ៉ាប់រង មានសិទ្ធិចុះកិច្ចព្រមព្រៀងធានារ៉ាប់រងបន្តចេញ ស្របតាមខ្លឹមសារនៃផែនការកិច្ចព្រមព្រៀងធានារ៉ាប់រងបន្ត ដែលទទួលបានការអនុញ្ញាតពី **ន.ធ.ក.**។ ក្រុមហ៊ុនធានារ៉ាប់រងបន្ត មានសិទ្ធិចុះកិច្ចព្រមព្រៀងធានារ៉ាប់រងបន្តចូល និងកិច្ចព្រមព្រៀងធានារ៉ាប់រងបន្តចេញ ស្របតាមខ្លឹមសារនៃផែនការកិច្ចព្រមព្រៀងធានារ៉ាប់រងបន្តដែលទទួលបានការអនុញ្ញាតពី **ន.ធ.ក.**។

កិច្ចព្រមព្រៀងធានារ៉ាប់រងបន្ត អាចជាប្រភេទសមាមាត្រ និង/ឬមិនសមាមាត្រ។

## ជំពូកទី៤
## គោលការណ៍ធានារ៉ាប់រងបន្ត

**ប្រការ១២ ..**

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវរៀបចំគោលការណ៍ធានារ៉ាប់រងបន្ត និងត្រូវស្នើសុំការអនុញ្ញាតពី **ន.ធ.ក.** ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីទទួលបានការសម្រេចពីក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន។

**ប្រការ១៣.-**

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវរៀបចំគោលការណ៍ធានារ៉ាប់រងបន្តឱ្យស្របទៅនឹងលក្ខណៈហានិភ័យ យុទ្ធសាស្ត្រអាជីវកម្ម និងកម្រិតនៃដើមទុន។ គោលការណ៍ធានារ៉ាប់រងបន្ត ត្រូវមានព័ត៌មានអប្បបរមាដូចខាងក្រោម៖

- ការកំណត់ និងយន្តការត្រួតពិនិត្យលើកម្រិតរក្សាទុកហានិភ័យតាមប្រភេទផលិតផលធានារ៉ាប់រង
- នីតិវិធីនៃការកំណត់ និងវាយតម្លៃហានិភ័យបង្គរ
- ការកំណត់ប្រភេទ និងសមត្ថភាពធានារ៉ាប់រងបន្ត
- ការជ្រើសរើស និងវាយតម្លៃក្រុមហ៊ុនធានារ៉ាប់រងបន្ត
- លក្ខខណ្ឌសម្រាប់ការប្រើប្រាស់ការធានារ៉ាប់រងបន្តក្រៅកិច្ចព្រមព្រៀងធានារ៉ាប់រងបន្តគោល។

**ប្រការ១៤.-**

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវស្នើសុំការអនុញ្ញាតពី **ន.ធ.ភ.** ក្នុងរយៈពេលយ៉ាងយូរ ៣០(សាមសិប) ថ្ងៃ បន្ទាប់ពីទទួលបានការសម្រេចពីក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ក្នុងករណីមានការផ្លាស់ប្ដូរ ឬកែប្រែគោលការណ៍ធានារ៉ាប់រងបន្ត។

**ប្រការ១៥.-**

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវពិនិត្យ និងវាយតម្លៃឡើងវិញលើគោលការណ៍ធានារ៉ាប់រងបន្ត យ៉ាងយូរ ៣ (បី) ឆ្នាំម្ដង។

## ជំពូកទី៥
## ពិពិធកម្មនៃការធានារ៉ាប់រងបន្ត

**ប្រការ១៦.-**

ក្រុមហ៊ុនធានារ៉ាប់រង អាចផ្ទេរហានិភ័យទៅក្រុមហ៊ុនធានារ៉ាប់រងបន្តក្នុងប្រទេស និង/ឬក្រៅប្រទេស។

**ប្រការ១៧.-**

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវផ្ទេរហានិភ័យដែលលើសពីកម្រិតរក្សាទុកហានិភ័យ ទៅក្រុមហ៊ុនធានា-រ៉ាប់រងបន្ត តាមលក្ខខណ្ឌដែលត្រូវកំណត់ដោយ **ន.ធ.ភ.**។

## ជំពូកទី៦
## កាតព្វកិច្ចផ្ដល់របាយការណ៍

**ប្រការ១៨.-**

ក្រុមហ៊ុនធានារ៉ាប់រង ត្រូវផ្ដល់របាយការណ៍សង្ខេបអំពីការធានារ៉ាប់រងបន្តមក **ន.ធ.ភ.** ឱ្យបានមុន

ថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់។

**ប្រការ១៩ .-**

របាយការណ៍សង្ខេបអំពីការធានារ៉ាប់រងបន្ត ត្រូវមានព័ត៌មានអប្បបរមា ដូចខាងក្រោម៖

- ព័ត៌មាននៃការធានារ៉ាប់រងបន្ត មានជាអាទិ៍៖ កម្រិតរក្សាទុកហានិភ័យ កម្រិតត្រូវធ្វើធានារ៉ាប់រងបន្ត និងចំនួនបុព្វលាភធានារ៉ាប់រងបន្តតាមក្រុមហ៊ុនធានារ៉ាប់រងបន្តនីមួយៗ
- ច្បាប់ចតចម្លងនៃកិច្ចសន្យាធានារ៉ាប់រងបន្ត
- សមាមាត្រនៃការធានារ៉ាប់រងបន្តចំពោះក្រុមហ៊ុនធានារ៉ាប់រងបន្តនាំមុខ និងក្រុមហ៊ុនធានារ៉ាប់រងបន្តចូលរួមនីមួយៗ
- ព័ត៌មានអំពីសំណងធានារ៉ាប់រងដែលបានទូទាត់ រួមទាំងសំណងធានារ៉ាប់រងបន្ទាន់ និងសំណងធានារ៉ាប់រងមិនទាន់ទូទាត់ពីក្រុមហ៊ុនធានារ៉ាប់រងបន្ត
- ព័ត៌មានទាក់ទងនឹងកិច្ចព្រមព្រៀងធានារ៉ាប់រងបន្តផ្សេងទៀត ដែលតម្រូវដោយ **ន.ធ.ក.**។

## ជំពូកទី៧
## ទោសប្បញ្ញត្តិ

**ប្រការ២០ .-**

ក្នុងករណីពិនិត្យឃើញថា ក្រុមហ៊ុនធានារ៉ាប់រងមិនអនុវត្តកាតព្វកិច្ច ស្របតាមការកំណត់ក្នុងប្រកាសនេះ **ន.ធ.ក.** អាចធ្វើការណែនាំ ឬការព្រមានជាលាយលក្ខណ៍អក្សរ ឬការកត់សម្គាល់ជាសាធារណៈ និងបញ្ជាឱ្យធ្វើការកែតម្រូវ។

ក្រុមហ៊ុនធានារ៉ាប់រងដែលប្រព្រឹត្តល្មើសនឹង ប្រការ៤ ប្រការ៥ ប្រការ៦ ប្រការ៧ ប្រការ៨ ប្រការ៩ ប្រការ១២ ប្រការ១៣ ប្រការ១៤ ប្រកា១៥ ប្រការ១៧ ប្រការ១៨ និងប្រការ១៩ នៃប្រកាសនេះ ត្រូវទទួលទណ្ឌកម្មខាងវិន័យណាមួយពី **ន.ធ.ក.** ដូចមានចែងក្នុងច្បាប់ស្ដីពីការធានារ៉ាប់រង និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន។

មុននឹងដាក់ទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងកថាខណ្ឌខាងលើ **ន.ធ.ក.** ត្រូវផ្ដល់ឱកាសឱ្យបុគ្គលប្រព្រឹត្តល្មើសធ្វើការស្រាយបំភ្លឺជាមុនសិន។

**ប្រការ២១ .-**

ការអនុវត្តបទប្បញ្ញត្តិនៃជំពូកទី៧ នៃប្រកាសនេះ មិនរារាំងដល់ការអនុវត្តច្បាប់ និងបទប្បញ្ញត្តិព្រហ្មទណ្ឌផ្សេងទៀត ក្នុងករណីដែលអំពើដែលប្រព្រឹត្តផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជាបទល្មើសដែលបានបញ្ញត្តក្នុងច្បាប់ និងបទប្បញ្ញត្តិព្រហ្មទណ្ឌផ្សេងទៀត។

## ជំពូកទី៨

## អវសានប្បញ្ញត្តិ

**ប្រការ២២ ._**

**ន.ធ.ក.** អាចចេញគោលការណ៍ណែនាំអនុលោមតាមច្បាប់ស្តីពីការធានារ៉ាប់រង អនុក្រឹត្យស្តីពីការធានារ៉ាប់រង និងប្រកាសនេះ ដើម្បីសម្រួលដល់ការយល់ដឹង និងការអនុវត្តតាមប្រកាសនេះ។

**ប្រការ២៣ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២៤ ._**

អគ្គនាយកនៃ **ន.ធ.ក.** ប្រធាននាយកដ្ឋានត្រួតពិនិត្យ គ្រប់ប្រធាននាយកដ្ឋានស្ថិតក្រោមចំណុះ **ន.ធ.ក.** និងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ តាមភារកិច្ចរៀងខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ៧កើត ខែ អាសាឍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែ កក្កដា គ.ស.២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**និងជាប្រធាន ក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងពាណិជ្ជកម្ម
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់អង្គភាពនិងសមាសភាពក្រុមប្រឹក្សានៃ **អ.ស.ហ.**
  "ដើម្បីជូនជ្រាប"
- ដូចប្រការ២៤
  "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ